# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

សាលាដំបូងរាជធានីភ្នំពេញ

-សំណុំរឿងព្រហ្មទណ្ឌ

លេខ ៣៦៧៦

ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥

-ដំណុំជម្រះលេខ ២៥០២

ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥

-សាលក្រមព្រហ្មទណ្ឌ

លេខ ២៧៦ ក្រ៤.ឋ-

ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការទី២ នាថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ វេលាម៉ោង៨ និង៣០នាទីព្រឹក ដោយមានសមាសភាពដូចខាងក្រោម៖

**<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>**

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

**<u>តំណាងអយ្យការ</u>**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**<u>ដើម្បីជំនុំជម្រះ</u>**

សំណុំរឿងព្រហ្មទណ្ឌលេ ៣៦៧៦ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ដែលមានជនជាប់ចោទ៖

-ឈ្មោះ [redacted] ភេទប្រុស អាយុ៣៣ឆ្នាំ ជាតិខ្មែរ មុខរបរ រើសអេតចាយ ទីកន្លែងកំណើត នៅផ្ទះជួល ភូមិព្រៃព្រីងត្បូង ឃុំចោមចៅ ស្រុកដង្កោ ខេត្តកណ្ដាល ទីលំនៅបច្ចុប្បន្នផ្ទះជួល ភូមិព្រៃព្រីងត្បូង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] - ម្ដាយឈ្មោះ [redacted] - ប្រពន្ធឈ្មោះ [redacted] - មានកូន០២នាក់ ជានីតិជន ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន ។

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ២៥៦១ តព្រ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ ។

-ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

-ជាប់ចោទពីបទ លួច និងប៉ុនប៉ងលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា(គាស់ផ្ទះទម្លាយ) ប្រព្រឹត្តនៅចំណុច ភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៧ និងមាត្រា ២៧ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ៥៦ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នផ្ទះលេខ៩E ភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

**១.<u>អង្គហេតុនៃរឿងមានដូចតទៅ</u>**

កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ វេលាម៉ោង០២ និង៣០នាទី ពេលដែលជនរងគ្រោះម្នាក់មិនស្គាល់ឈ្មោះកំពុងដេកនៅតូបលក់ដូរតាមចិញ្ចើមផ្លូវ ភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដោយទុកទូរស័ព្ទ០១គ្រឿង ម៉ាកណូគា ពណ៌ខ្មៅ នៅក្រៅក្បែរខ្លួន ស្រាប់តែជនត្រូវចោទឈ្មោះ [redacted] ដែលជាអ្នកដើររើសអេតចាយ បានធ្វើសកម្មភាពលួចយកទូរស័ព្ទដៃរបស់ជនរងគ្រោះ



Scanned by CamScanner

ហើយបានបន្តទៅផ្ទះរបស់ជនរងគ្រោះម្នាក់ទៀតឈ្មោះ[redacted]ភេទប្រុស ស្ថិតនៅភូមិសង្កាត់ខាងលើដែរ រួចបានលួចយកដែកសរសៃមួយដើមនៅក្បែរផ្ទះរបស់ជនរងគ្រោះ ហើយបានធ្វើសកម្មភាពគាស់សោរទ្វា ខាងក្រោយផ្ទះរបស់ជនរងគ្រោះបំណងចូលលួចទ្រព្យសម្បត្តិផ្សេងទៀត តែត្រូវជនរងគ្រោះដឹងខ្លួន ក៏បានស្រែកថាចោរភ្លាមនោះប្រជាពលរដ្ឋរស់នៅក្បែរនោះ ក៏បាននាំគ្នាចាប់ឃាត់ខ្លួនជនត្រូវចោទបាន រួចប្រគល់ជូនសមត្ថកិច្ចតែម្តង ។

-បានឃើញ របាយការណ៍សំយោគលេខ ១៧៣/០១៥ របក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ របស់អធិការនគរបាលខណ្ឌពោធិ៍សែនជ័យ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យលេខ ២៣៥៨ អ.យ.ន ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥ របស់លោក[redacted]ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ២៥៩៨ អ.យ.ន ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់លោក[redacted]ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ៥៩១៤ ដ.ជ.រ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ ២០១៥ របស់លោក[redacted]ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាបង្គាប់ឲ្យនាំជនជាប់ចោទមកសាលាដំបូងរាជធានីភ្នំពេញលេខ ២២៣ ព្រ.ទ ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០១៦ របស់លោក[redacted]ព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញ ។

## ២.**នាពេលសវនាការ**

២.១-ជនជាប់ចោទឈ្មោះ[redacted]បានឆ្លើយថា នៅថ្ងៃកើតហេតុនោះ ខ្លួនបានជិះកង់ដើររើសអេតចាយមកដល់ចំណុច ភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ក៏បានឃើញបុរសម្នាក់ស្រវឹងស្រាដេកនៅតូបលក់ដូរតាមចិញ្ចើមផ្លូវ ដោយទុកទូរស័ព្ទ០១គ្រឿង ម៉ាកណូគា នៅគ្រែក្បែរខ្លួនគាត់ ហើយខ្លួនក៏បានយកទូរស័ព្ទនោះតែម្តង ។ ហើយខ្លួនក៏បានដើរបន្តទៅដល់កន្លែងកើតហេតុ ផ្ទះលេខ៥E សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ខ្លួនក៏បានឃើញដែកថ្នាំងអំពៅ១ដើម ខ្លួនក៏បានចូលទៅកាច់បត់ដែកនោះបំណងលើកដាក់លើកង់ ហើយក៏ត្រូវជនរងគ្រោះឃើញ ក៏ស្រែកថាចោរៗ ភ្លាមនោះក៏មានប្រជាពលរដ្ឋចាប់បាន និងវាយខ្លួនរួចប្រគល់អោយសមត្ថកិច្ចតែម្តង ។ ខ្លួនពុំបានធ្វើសកម្មភាពគាស់សោរទ្វាផ្ទះរបស់គេនោះទេ ។ ចំពោះដែកកាប់ កូនសោរលេខ៨ កាំបិតចុងស្រួចដងជ័រ ដែលសមត្ថកិច្ចចាប់ និងឃាត់ខ្លួននោះ គឺខ្លួនបានរើសពីមុខកន្លែងគេធ្វើម៉ូតូក្បែរកន្លែងកើតហេតុ គឺមិនមែនឧបករណ៍ទុកសម្រាប់គាស់ទ្វាផ្ទះគេនោះទេ ។

២.២-ក្រឡាបញ្ជីអានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]នៅសមត្ថកិច្ចនគរបាលបានឆ្លើយថា កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ ខ្លួនកំពុងសម្រាកនៅក្នុងផ្ទះរបស់ខ្លួន នៅភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ លុះដល់ម៉ោង២ និង៣០នាទី ខ្លួនបានក្រោកពីដំណេកក៏ប្រទះឃើញបុរសម្នាក់ ឈរក្នុងផ្ទះរបស់ខ្លួន ខ្លួនស្មានតែជាកូនប្រុស តែពេលបើកភ្លើងទើបដឹងថាមិនមែនកូនខ្លួន ហើយបុរសនោះក៏លោតចេញតាមបង្អួចខាងក្រោយ ។ បន្ទាប់មកបានប្រហែល៣០នាទីក្រោយមកបុរសម្នាក់នោះក៏បានធ្វើសកម្មភាពគាស់សោរទ្វាខាងក្រោយផ្ទះរបស់ខ្លួន ហើយពេលនោះក៏បាន ស្រែកថាចោរៗ ហើយវាក៏បានអូសដែកសរសៃរបស់ខ្លួននៅខាងក្រោយផ្ទះទៅជាមួយផង ក៏មានអ្នកជិតខាងឃាត់ខ្លួនជូនសមត្ថកិច្ចតែម្តង ។

២.៣-ក្រឡាបញ្ជីអានចម្លើយរបស់សាក្សីឈ្មោះ[redacted]នៅសមត្ថកិច្ចនគរបាលបានឆ្លើយថា នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល២ និង៣០នាទី លោកប្រធានភូមិត្រពាំងពោធិ៍ បានទូរស័ព្ទមកប្រាប់ខ្លួនថា មានប្រជាពលរដ្ឋក្នុងភូមិមកប្រាប់គាត់ថា ពួកគាត់ចាប់បានចោរម្នាក់ដែចូលលួច



Scanned by CamScanner

ទ្រព្យសម្បត្តិរបស់ពួកគាត់ ហើយគាត់បានឲ្យខ្លួនទៅជួយអន្តរាគមន៍ ក្រែងប្រជាពលរដ្ឋវាយពួកខ្លួនស្លាប់ ។ ពេលដែលខ្លួនទៅដល់កន្លែងកើតហេតុ ឃើញស្ថានភាពចោរនោះត្រូវប្រជាពលរដ្ឋវាយទ្រោមខ្លួនទៅហើយ និងឈ្មោ[redacted]បាននាំខ្លួនចោរនោះ និងវត្ថុតាងមួយចំនួនទៅប្រគល់ជូនសមត្ថកិច្ចតែម្តង ។

២.៨-ក្រឡាបញ្ជីអានកំណត់ហេតុទទួលវត្ថុចាប់យកលេខ ១១៧៩ អ.យ.ន ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញរួមមានដូចខាងក្រោម៖

-ដែកចុងស្រួចតូចៗ ចំនួន០២ (ដែកកាំកង់) ។

-ទូណឺវីស ចំនួន០១គ្រឿង ។

-ដែកកាប់ចំនួន០១ ។

-កូនសោខ្សៀ ទំហំលេខ៨ ចំនួន០១ ។

-កូនកំបិតដងខ្មៅចំនួន០១ ។

-ទូរស័ព្ទដៃម៉ាក Camfone ពណ៌ផ្កាឈូក លាយខ្មៅ ចំនួន០១គ្រឿង ។

-ទូរស័ព្ទដៃម៉ាក Nokia ពណ៌ខ្មៅ ចំនួន០១គ្រឿង ។

## ៣.៥.សេចក្តីសន្និដ្ឋានថ្លែងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានស្តាប់ការសាកសួរដេញដោលនាពេលសវនាការរួចមកឃើញថា ជនជាប់ចោទឈ្មោះ[redacted]នឆ្លើយសារភាពថាខ្លួនពិតជាបានលួចយកទូរស័ព្ទជនរងគ្រោះដែលបានដេកលក់នៅតាមចិញ្ចើមផ្លូវពិតមែន ក៏ប៉ុន្តែបានឆ្លើយបដិសេធថាខ្លួនពុំបានឆ្កិះសោរទ្វាររបស់ជនរងគ្រោះនោះទេ ដែលនេះគ្រាន់តែចម្លើយឆ្លើយដោះបន្ទុក ក្នុងចេតនាគេចវេសពីការទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះអំពើដែលខ្លួនបានប្រព្រឹត្តនោះ និងពុំមានភស្តុតាងណាមួយដោះបន្ទុក នោះទេ ហេតុនេះតំណាងអយ្យការសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ២៥៩៨ អ.យ.ន ចុះថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ២០១៥ ទុកជាបានការដដែល និងសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់ ។

## ៣.៦.សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឲ្យជនជាប់ចោទ

-លោក[redacted]ជាមេធាវីការពារឲ្យសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីស្តាប់ការសាកសួរដេញដោលនាពេលសវនាការនេះរួចមកឃើញថា កូនក្តីរបស់ខ្លួនបានឆ្លើយសារភាពថា ខ្លួនពិតជាបានធ្វើសកម្មភាពលួចយកទូរស័ព្ទជនរងគ្រោះដែលបានដេកលក់ដួរនៅតាមចិញ្ចើមផ្លូវពិតមែន ក៏ប៉ុន្តែកូនក្តីខ្លួនបានឆ្លើយបញ្ជាក់រួចហើយថា ខ្លួនពុំបានធ្វើសកម្មភាពគាស់ សោរទ្វាផ្ទះរបស់គេនោះទេ ហើយចំពោះឧបករណ៍ដែលសមត្ថកិច្ចឃាត់ខ្លួននោះ គឺកូនក្តីខ្លួនបានបញ្ជាក់ហើយថា រើសបានពីមុខកន្លែងគេធ្វើម៉ូតូក្បែរកន្លែងកើតហេតុ គឺមិនមែនឧបករណ៍ទុកសម្រាប់គាស់ទ្វាផ្ទះគេនោះទេ ហេតុនេះសូមក្រុមប្រឹក្សាជំនុំជម្រះពិចារណា និងសម្រេចលើកលែងចោទប្រកាន់កូនក្តីខ្លួនពីបទប៉ុនប៉ងលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា (គាស់ទម្លុះទម្លាយ) ដល់កូនក្តីខ្លួនផង ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោ[redacted]ាននិយាយសំដីចុងក្រោយបង្អស់ថា សូមតុលាការមេត្តាលើកលែងចោទប្រកាន់ដល់ខ្លួនផង ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី



Scanned by CamScanner

-ក្រោយពីបានស្តាប់អំណានឯកសារក្នុងសំណុំរឿង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារភស្តុតាងត្រឹមត្រូវហើយ

-ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ

## ៣.**សំអាងហេតុ**

៣.១-តាមរបាយការណ៍សំយោគលេខ ១៧៣/០១៥ របក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ របស់អធិការនគរបាលខណ្ឌពោធិ៍សែនជ័យបញ្ជាក់ថា ពិតជាករណី លួច និងប៉ុនប៉ងលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា(គាស់ទម្លុះទម្លាយ) កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ ប្រព្រឹត្តនៅចំណុចភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដែលបង្កឡើងដោយឈ្មោះ [redacted] ពិតប្រាកដមែន ។

៣.២-តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤៩១៤ ដ.ជ.រ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៤ បានបញ្ជូនជនជាប់ចោទដែលមានឈ្មោះ [redacted] មកជំនុំជម្រះពីបទ លួច និងប៉ុនប៉ងលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា(គាស់ទម្លុះទម្លាយ) បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ ,មាត្រា ៣៥៧ និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ។

៣.៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា ខ្លួនពិតជាបានធ្វើសកម្មភាពលួចយកទូរស័ព្ទជនរងគ្រោះដែលបានដេកលក់នៅតាមចិញ្ចើមផ្លូវពិតមែន ក៏ប៉ុន្តែជនជាប់ចោទបានបដិសេធថាពុំបានធ្វើសកម្មភាពគាស់សោរទ្វាផ្ទះរបស់គេនោះទេ ហើយចំពោះឧបករណ៍ដែលសមត្ថកិច្ចចាប់យាត់ទុកគឺជនជាប់ចោទបានរើសបានពីមុខកន្លែងគេធ្វើម៉ូតូក្បែរកន្លែងកើតហេតុ គឺមិនមែនឧបករណ៍ទុកសម្រាប់គាស់ទ្វាផ្ទះគេនោះទេ ចម្លើយនេះគ្រាន់តែជាចម្លើយឆ្លើយដោះសារដើម្បីចេតនាគេចវេសពីការទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះអំពើដែលខ្លួនបានប្រព្រឹត្តតែប៉ុណ្ណោះ និងពុំមានភស្តុតាងណាមួយដើម្បីឲ្យតុលាការជឿបានទេ ។

៣.៤-តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] នៅថ្ងៃកើតហេតុនោះពេលជនជាប់ចោទកំពុងសម្រាកនៅក្នុងផ្ទះ ហើយនៅពេលជនរងគ្រោះបានក្រោកពីដំណេក ក៏ប្រទះឃើញបុរសម្នាក់ឈរក្នុងផ្ទះ ស្មានតែជាកូនប្រុស លុះពេលបើកភ្លើងទើបដឹងថាមិនមែនជាកូន ហើយបុរសនោះក៏លោត ចេញតាមបង្អួចខាងក្រោយ ។ បន្ទាប់មកបានប្រហែល៣០នាទីក្រោយមក ជនសង្ស័យម្នាក់នោះក៏បានធ្វើសកម្មភាពគាស់សោរទ្វាខាងក្រោយផ្ទះរបស់ជនរងគ្រោះ ពេលនោះជនរងគ្រោះដឹងទាន់ក៏បានស្រែកថាចោរៗ ហើយជនជាប់ចោទក៏បានរូសដែកសរសៃរបស់ជនរងគ្រោះនៅខាងក្រោយផ្ទះទៅជាមួយផងពេលនោះក៏មានអ្នកជិតខាងឃាត់ខ្លួនជូនសមត្ថកិច្ចតែម្តង ។

៣.៥-នៅពេលសមត្ថកិច្ចចាប់ខ្លួនជនជាប់ចោទ ដកហូតបានវត្ថុតាងដូចមានក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ១១៧៩ អ.យ.ន ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញរួមមានដូចខាងក្រោម៖

-ដែកចុងស្រួចតូចៗ ចំនួន០២ (ដែកកាំកង់) ។

-ទួណឺវីស ចំនួន០១គ្រឿង ។

-ដែកកាប់ចំនួន០១ ។



Scanned by CamScanner

-កូនសោខៀវ ទំហំលេខ៨ ចំនួន០១ ។
-កូនក់បិតដងខ្មៅចំនួន០១ ។
-ទូរស័ព្ទដៃម៉ាក Camfone ពណ៌ផ្កាឈូក លាយខ្មៅ ចំនួន០១គ្រឿង ។
-ទូរស័ព្ទដៃម៉ាក Nokia ពណ៌ខ្មៅ ចំនួន០១គ្រឿង ។
គប្បីតុលាការពិចារណា ។

៣.៦-តាមរបាយការណ៍របស់សមត្ថកិច្ច ចម្លើយរបស់ជនជាប់ចោទ ,អំណានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សីឈ្មោះ[redacted]ព្រមទាំងវត្ថុតាងដែលដកហូតបានពីជនជាប់ចោទអាចបញ្ជាក់បានថាជនជាប់ចោទឈ្មោះ [redacted]ពិតជាបានប្រព្រឹត្តអំពើ លួច និងប៉ុនប៉ងលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា (គាស់ទម្លុះទម្លាយ) ពិតប្រាកដមែន ។

៣.៧-អំពើរបស់ជនជាប់ចោទ ដែលបានលួចយកទូរស័ព្ទដៃរបស់អ្នកដទៃដែលកំពុងដេកលក់ និងបន្តទៅគ្លឹះសោរទ្វាផ្ទះចូលលួចរបស់អ្នកដទៃម្នាក់ទៀតដើម្បីយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន អំពើនេះ គឺជាអំពើល្មើសដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៧ និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ថាជាអំពើ លួច និងប៉ុនប៉ងលួច មានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា(គាស់ទម្លុះទម្លាយ) ។

៣.៨-តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋាន មានមូលដ្ឋានគ្រប់គ្រាន់ដើម្បីបញ្ជាក់ពីកម្រុយពិរុទ្ធភាពរបស់ជនជាប់ចោទ ។

៣.៩-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានថា សុំក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិចារណា និងសម្រេចលើកលែងចោទប្រកាន់កូនក្ដីខ្លួនពីបទ ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា(គាស់ទម្លុះទម្លាយ) វិញផង ។ គប្បីតុលាការពិចារណា ។

៣.១០-មានភស្ដុតាងដាក់បន្ទុក និងមានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted]ភេទប្រុស អាយុ៣៣ឆ្នាំ ជាតិខ្មែរ ជាប់ចោទពីបទ លួច និងប៉ុនប៉ងលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា(គាស់ទម្លុះទម្លាយ) ប្រព្រឹត្តនៅចំណុច ភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៧ និងមាត្រា ២៧ នៃក្រមព្រហ្មទណ្ឌ ។

៣.១២-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ[redacted]ពុំបានបញ្ជាក់អំពីការប្ដឹងទាមទារសំណងថ្លៃបាត់បង់ និងជម្ងឺចិត្តនោះទេ គប្បីទុកសិទ្ធិឲ្យដើមបណ្ដឹងរដ្ឋប្បវេណីទាមទារសំណងនៅពេលក្រោយ ។

៣.១៣-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ[redacted] សុំឲ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់ខ្លួនផង ដោយខ្លួនបានដឹងកំហុសហើយ ។ ចំណុចនេះតុលាការនឹងពិចារណា ។

## ៤.ហេតុដូច្នេះសម្រេច

៤.១-ផ្ដន្ទាទោស៖

-ឈ្មោះ[redacted]ភេទប្រុស អាយុ៣៣ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០៣ឆ្នាំ (បីឆ្នាំ) ពីបទ លួច និងប៉ុនប៉ងលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា (គាស់ទម្លុះទម្លាយ) ប្រព្រឹត្តនៅចំណុចភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៧ និងមាត្រា ២៧ នៃក្រមព្រហ្មទណ្ឌ ។

៤.២-វត្ថុចាប់យកត្រូវរឹបអូសតាមមាត្រា ៦២ និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌគឺ:
-ដែកចុងស្រួចតូចៗ ចំនួន០២(ដែកកាំកង់) ។
-ទួណឺវីសចំនួន០១ ។



Scanned by CamScanner

-ដែកកាប់ចំនួន០១ ។

-កូនសោខៀវទំហំលេខ៨ ចំនួន០១ ។

-កូនកំបិតដងខ្មៅចំនួន០១ ។

៤.៣-វត្ថុចាប់យកត្រូវប្រគល់ឲ្យម្ចាស់ដើមវិញតាមមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌគឺៈ

-ទូរស័ព្ទដៃម៉ាក Camfone ពណ៌ផ្កាឈូក លាយខ្មៅ ចំនួន០១គ្រឿង ។

-ទូរស័ព្ទដៃម៉ាក Nokia ពណ៌ខ្មៅ ចំនួន០១គ្រឿង ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ម៉ែន វុត្ថា និងប្រកាសជាសាធារណៈនៅថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០១៦ ។

-បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា៖ | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា និងត្រា៖ |
| [redacted] | [redacted] | [redacted] | [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

ក្រឡាបញ្ជី

[redacted]



Scanned by CamScanner